គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL

ភ្នំពេញ, ថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១

# សេចក្តីប្រកាសព័ត៌មាន

ក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជា មានកិត្តិយសជម្រាបជូនសាធារណៈជន អ្នកសារព័ត៌មានជាតិ-អន្តរជាតិ វិទ្យុ ទូរទស្សន៍ តំណាងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ និងតំណាងអង្គទូតឲ្យបានជ្រាបថា នៅថ្ងៃទី ០២ ខែតុលា ឆ្នាំ២០១៤ ក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជានឹងរៀបចំសន្និសីទសារព័ត៌មានស្តីពី « **សារាចរណែនាំរបស់ប្រធានរដ្ឋសភាមិនស្របតាមក្របខ័ណ្ឌច្បាប់ និងគោលការណ៍ប្រសិទ្ធិភាព តម្លាភាព និងប្រជាធិបតេយ្យ**»។

កាលបរិច្ឆេទ៖ ថ្ងៃទី០២ ខែតុលា ២០១៤

វេលាម៉ោង៖ ៩:៣០ ព្រឹក

ទីកន្លែង៖ ស្នាក់ការកណ្តាលអង្គការខុមហ្វ្រែល

រៀបចំដោយ៖ ក្រុមអង្គការសង្គមស៊ីវិល

## វាគ្មិនចូលរួមសំខាន់ៗរួមមាន៖

- លោក គល់ បញ្ញា — នាយប្រតិបត្តិអង្គការ ខុមហ្វ្រែល
- លោក នី ចរិយា — ប្រធានផ្នែកអង្កេតនៃសមាគម អាដហុក
- លោក អ៊ូ វីរៈ — ប្រធានក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

អាស្រ័យដូចបានជម្រាបជូនខាងលើ យើងខ្ញុំសូមគោរពអញ្ជើញសាធារណៈជន អ្នកសារព័ត៌មានជាតិ-អន្តរជាតិ វិទ្យុ ទូរទស្សន៍ តំណាងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ និងតំណាងអង្គទូត ចូលរួមក្នុងកិច្ចសន្និសីទសារព័ត៌មាននេះ កុំបីខាន។ព័ត៌មានបន្ថែមសូមទាក់ទង៖ ០២៣ ៨៨៤ ១៥០ / ០៨៩ ២១ ២១ ១០

**បេសកកម្ម** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/**ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ទស្សនៈវិស័យ ៖ ដើម្បីឱ្យការបោះឆ្នោតមានអត្ថន័យ ដែលប្រកបដោយការចូលរួមពីប្រជាពលរដ្ឋ

**ទីស្នាក់ការកណ្តាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**Central Office** : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org